នស/រកត/០៩០៨/៩៧៥

# ព្រះរាជក្រឹត្យ

## ស្ដីពីការកែសម្រួលព្រះរាជក្រឹត្យ

## លេខ នស/រកត/០៨០៧/៣៩៣ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៧

## ស្ដីពីការកែសម្រួលព្រះរាជក្រឹត្យ

## លេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២

## ស្ដីពីការបង្កើតឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

**យើង**

**ព្រះករុណាព្រះបាទ សម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្ដីពីការបង្កើតឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៧/៣៩៣ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៧ ស្ដីពីការកែសម្រួលព្រះរាជក្រឹត្យ លេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្ដីពីការបង្កើតឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE * ROYAL * [illegible]

## ត្រាស់បង្គាប់

**មាត្រាមួយ :**

ត្រូវបានកែសម្រួលមាត្រា ៤ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៧/៣៩៣ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យ លេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ មានខ្លឹមសារដូចខាងក្រោម :

**មាត្រា ៤ ថ្មី :**

*កឧស* មានប្រធានកិត្តិយសមួយរូប ដែលត្រូវបានជ្រើសរើសឡើងពីក្នុងចំណោមឥស្សរជន ដែលមានគុណសម្បត្តិ ក្នុងការបម្រើប្រទេសជាតិ មានបទពិសោធន៍ខ្ពស់ និងមានការទទួលស្គាល់ក្នុងមជ្ឈដ្ឋានជាតិ និងនៅលើឆាកអន្តរជាតិ ។ ប្រធានកិត្តិយស *កឧស* អាចមានឋានៈស្មើ ឧបនាយករដ្ឋមន្ត្រី ឬ ទេសរដ្ឋមន្ត្រី ។

**មាត្រាពីរ :**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រាបី :**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ចរល.០៨០៧.៩៩៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

នៃព្រះរាជាណាចក្រកម្ពុជាសូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ៩៣២ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ... ឆ្នាំ២០០៨

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

... ចិនកេន